# ទឹកភ្នែកកម្មករ

លំនាំបទ: លាហើយប៉ៃលិន

១. ទឹកភ្នែកខ្ញុំហូរៗព្រោះរឿងអ្វី ញាតិទាំងប្រុសស្រីអ្នកដឹងរឺទេ
ខ្ញុំខំធ្វើការឥតមានទំនេរ ទាំងនេះព្រោះតែជីវភាពគ្រួសារ ។

២. ពេលឈឺសុំច្បាប់ប្រញាប់ព្យាបាល គេក្រវីក្បាលឆ្លើយថាមិនបាន
ព្រះអើយមើលចុះចិត្តគេសាមាន្យ គេមិនដែលបានគិតដល់យើងឡើយ ។

បន្ទរ. នេះហើយជីវិតកម្មករកាត់ដេរ មិនហ៊ានឈប់ទេព្រោះតែសុំច្បាប់មិនបាន
ធ្វើការទាំងឈឺមិនដែលបំពាន បើសិនជាហ៊ានថៅកែកាត់ប្រាក់ខែហើយ ។

៣. ឱ!ទឹកភ្នែកអើយអ្នកឈប់ហូរទៅ ទោះបីជានៅក៏គ្មានន័យអ្វី
យើងត្រូវរឹងមាំក្នុងនាមជាស្រី ត្រូវមានស្មារតីហ៊ានតស៊ូប្តូរ ។